**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៨៣/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ការបរទេសលើកទី១ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

**រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥**

កិច្ចប្រជុំពិគ្រោះយោបល់ការបរទេសលើកទី១ រវាងក្រសួងការបទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ត្រូវបានរៀបចំឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ កិច្ចប្រជុំនេះ ដឹកនាំដោយ**ឯកឧត្តមបណ្ឌិត អ៊ុន យាង** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និង**ឯកឧត្តមបណ្ឌិត ម៉ូហាម៉ាដ ណាហ្សុរុល អ៊ីស្លាម** (Md. Nazrul Islam) អនុរដ្ឋមន្ត្រីការបរទេសទទួលបន្ទុកកិច្ចការទ្វេភាគី និងជាអគ្គាធិការទទួលបន្ទុកស្ថានបេសកកម្មបង់ក្លាដែស នៃក្រសួងការបរទេសបង់ក្លាដែស។ សមាសភាពគណៈប្រតិភូកម្ពុជាក៏មានពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនផងដែរ។

ក្នុងអំឡុងពេលកិច្ចពិគ្រោះយោបល់ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈអំពីការវិវត្តនយោបាយ និងសង្គម-សេដ្ឋកិច្ច នៅក្នុងប្រទេសរៀងៗខ្លួន ក៏ដូចជាអំពីបញ្ហាតំបន់ និងអន្តរជាតិ។ កម្ពុជាសាទរចំពោះការលើកឡើងរបស់ភាគីបង់ក្លាដែស ស្តីពីវឌ្ឍនភាពរបស់ខ្លួនឆ្ពោះទៅរកការចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួចបំផុត (LDC) ដែលរំពឹងទុកនៅឆ្នាំ២០២៦ និងបានសម្តែងការកោតសរសើរចំពោះការចែករំលែកពីបទពិសោធន៍អភិវឌ្ឍន៍របស់ប្រទេសបង់ក្លាដែស។

ភាគីទាំងពីរក៏បានពិភាក្សាយ៉ាងទូលំទូលាយអំពីមធ្យោបាយនានា ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីបន្ថែមទៀត និងបានឯកភាពគ្នាជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យអទិភាព រួមមានពាណិជ្ជកម្ម និងវិនិយោគ ទេសចរណ៍ សុខាភិបាល កសិកម្ម និងនេសាទ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជន។

ចំពោះទំនាក់ទំនងនយោបាយ និងការទូត ប្រទេសទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចពិភាក្សាជាប្រចាំ ការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ និងការប្រាស្រ័យទាក់ទងប្រកបដោយថេរភាពតាមរយៈយន្តការដែលបានបង្កើតឡើង រួមមានគណៈកម្មការចម្រុះ ការពិគ្រោះយោបល់បរទេស និងវេទិកាទ្វេភាគីផ្សេងៗទៀត។ ភាគីទាំងពីរបានគូសបញ្ជាក់ថា យន្តការទាំងនេះជួយត្រួសត្រាយផ្លូវសម្រាប់ការរីកលូតលាស់នៃទំនាក់ទំនងកម្ពុជា និងបង់ក្លាដែស និងបានបង្ហាញបំណងប្រាថ្នារួមគ្នាក្នុងការជំរុញឱ្យមានដំណើរទស្សនកិច្ចកម្រិតខ្ពស់នាពេលអនាគត។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ចំពោះកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងការវិនិយោគ ភាគីទាំងពីរបានសាទរចំពោះនិន្នាការកើនឡើង ក្នុងទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគី និងបានលើកទឹកចិត្តឱ្យស្ថាប័នពាក់ព័ន្ធធ្វើការជិតស្និទ្ធបន្ថែមទៀត ដើម្បីពង្រីករំហូរពាណិជ្ជកម្ម និងការវិនិយោគ។ ភាគីទាំងពីរក៏បានពិភាក្សាពីសារៈសំខាន់នៃការអនុវត្តប្រកបដោយប្រសិទ្ធភាព និងការធ្វើបច្ចុប្បន្នភាពនូវក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគមួយចំនួនដើម្បីឆ្លើយតបទៅនឹងតថភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងសក្តានុពលនៅក្នុងវិស័យទាំងនេះ។

ភាគីទាំងពីរក៏បានអះអាងជាថ្មីពីសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យការពារជាតិ និងសន្តិសុខ ដែលជាវិធានកសាងទំនុកចិត្ត រួមចំណែកដល់ការកសាងសមត្ថភាពស្ថាប័ន សន្តិភាព និងស្ថិរភាព។ ភាគីទាំងពីរបានឯកភាពបន្តកិច្ចសហប្រតិបត្តិការទៅតាមភាពជាក់ស្តែងនិយម ស្របតាមច្បាប់ និងវិធានជាតិ និងអន្តរជាតិ។

ភាគីទាំងពីរក៏បានរំលេចពីសារៈសំខាន់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើកិច្ចការកុងស៊ុល ដើម្បីការពារសិទ្ធិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋរៀងៗខ្លួន។

ចំពោះកិច្ចសហប្រតិបត្តិការសង្គម-វប្បធម៌ ភាគីទាំងពីរបានកត់សម្គាល់ដោយការពេញចិត្ត ចំពោះកិច្ចសហប្រតិបត្តិការដែលមានក្នុងវិស័យការតភ្ជាប់ ទេសចរណ៍ សុខាភិបាល កសិកម្ម និងនេសាទ។ ភាគីទាំងពីរបានលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធ ធ្វើការពន្លឿនកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នាដែលកំពុងចរចារ ដើម្បីប្រែក្លាយជាកាតាលីករជំរុញឱ្យមានការកើនឡើងនៃការតភ្ជាប់រវាងប្រជាជន និងប្រជាជន ក៏ដូចជាការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៃប្រទេសទាំងពីរ។

ក្នុងអំឡុងពេលស្នាក់នៅកម្ពុជា **ឯកឧត្តមបណ្ឌិត** Md. Nazrul Islam ក៏បានចូលជួបសម្តែងការគួរសមចំពោះ **លោកជំទាវ អ៊ាត សោភា** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ភាគីទាំងពីរបានពិភាក្សាលើការជំរុញទំនាក់ទំនងរវាងកម្ពុជា និងបង់ក្លាដែស និងផ្នែកសំខាន់ៗនៃកិច្ចសហប្រតិបត្តិការទ្វេភាគី។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិ រួមទាំងអំពីការវិវត្តថ្មីៗពាក់ព័ន្ធនឹងស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ។

កិច្ចប្រជុំពិគ្រោះយោបល់លើកទី១ បានប្រព្រឹត្តទៅក្នុងបរិយាកាសមិត្តភាព និងស្ថាបនា ដែលឆ្លុះបញ្ចាំងពីការយោគយល់គ្នាទៅវិញទៅមក និងសេចក្តីប្រាថ្នារួមគ្នា ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។ ភាគីទាំងពីរបានព្រមព្រៀងគ្នារៀបចំកិច្ចពិគ្រោះយោបល់ការបរទេសលើកទី២ នៅប្រទេសបង់ក្លាដែស ទៅតាមកាលបរិច្ឆេទសមស្រប។

ភាគីបង់ក្លាដែសបានសម្តែងការអរគុណយ៉ាងជ្រាលជ្រៅចំពោះការស្វាគមន៍ និងបដិសណ្ឋារកិច្ចដ៏កក់ក្តៅដែលកម្ពុជាបានផ្តល់ជូនក្នុងអំឡុងពេលស្នាក់នៅរាជធានីភ្នំពេញ។

ថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥